# ដើម្បីផ្ទេរអំណាចបាន មនុស្សត្រូវតែមានអំណាចជាមុនសិន

**ដោយ ឡូរ៉ា ម៉ាក់ដូណល់**

**ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

ថ្ងៃនេះ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានបន្តផ្តើកសិណសាក្សីទាក់ទិននឹងដំណើរប្រតិបត្តិការរបស់គុកព្រៃស (មន្ទីរស-២៨) ដែលជាកន្លែងឃុំឃាំងសម្ងាត់មួយទៀតស្ថិតនៅក្រោមគ្រប់គ្រងរបស់ ឌុច ។ ដោយសារតែរយៈពេលខ្លីផ្តល់ឲ្យដោយចៅក្រមអង្គជំនុំជម្រះ ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ រួមទាំងមេធាវីការពារក្តី ចោទសំណួរទៅកាន់ ឌុច លើប្រធាននេះត្រឹមតែរយៈពេល៣ម៉ោងប៉ុណ្ណោះ ។

## តើមន្ទីរស-២៨បង្កើតឡើងក្នុងគោលបំណងអ្វី?

ដូចដែលបានបញ្ជាក់យ៉ាងច្បាស់កាលពីម្សិលមិញនេះ មន្ទីរស-២៨មានតួនាទីជា«កន្លែងកសាងខ្លួន» ប៉ុន្តែតាមការពិត មន្ទីរស-២៨គឺជាកន្លែងលុតដំការងារពលិកម្មទៅវិញទេ ពីព្រោះថា កន្លែងកសាងខ្លួននេះ គ្មានលទ្ធភាពនឹងសម្រេចបានលទ្ធផលកសាងមនុស្សដោយភាពងាយស្រួលនោះទេ ។ អ្នកទោសទាំងអស់ដែលត្រូវបានហៅថា ជា«សមាសធាតុ» នៅមន្ទីរស-២៨ដែលត្រូវបញ្ជូនទៅកាន់គុកទួលស្លែង (មន្ទីរស-២១) ដើម្បីសួរចម្លើយ និងធ្វើទារុណកម្ម ឬបញ្ជូនទៅវាលពិឃាតបឹងជើងឯក ដើម្បីសម្លាប់តែម្តង ។ មានឯកសារមួយច្បាប់និយាយពីករណីលើកលែងមួយដែលកងឈ្លបចំនួន៣០នាក់ត្រូវបានបញ្ជូនត្រឡប់មកកងយោធាវិញ ។

ប៉ុន្តែ ឌុច បានបដិសេធថា មិនមានហេតុការណ៍ដូច្នេះកើតឡើងនោះទេ ។ ម្តង ឌុច បានយល់ស្របថាការដោះលែងគឺមិនអាចធ្វើទៅរួចបានទេ ម្តង ឌុច និយាយថា មន្ទីរស-២៨ ខុសពីមន្ទីរស-២១ត្រង់ថា ប្រសិនបើអ្នកទោសខិតខំប្រឹងប្រែងធ្វើការ និងគោរពតាមគោលនយោបាយបក្ស នោះអ្នកទាំងនោះអាចមានលទ្ធភាពរួចខ្លួនបាន ។ មនុស្សនៅមន្ទីរស-២៨ មិនត្រូវបានកម្ទេចដោយគ្មានមូលហេតុនោះទេ ។

មូលហេតុចម្បងដែលអ្នកទោសទាំងអស់ត្រូវបញ្ជូនទៅកាន់មន្ទីរស-២១ ឬបឹងជើងឯក គឺដោយសារតែមានការសង្ស័យថា អ្នកទោសទាំងនោះមានគម្រោងប្រឆាំង ឬលួចរត់។ ប្រហែលជាវាមានភាពងាយស្រួលបំផុតក្នុងការស្វែងរក«មូលហេតុ»ដើម្បីបញ្ជូនមនុស្សទៅកម្ទេចចោល ដូច្នេះហើយបានជានរណាក៏ដោយ ក៏អាចត្រូវកម្ទេចចោលដែរ។ ក្រោយពីត្រូវបានបង្ខំឲ្យធ្វើការងារធ្ងន់នៅក្រោមកំដៅថ្ងៃដ៏ក្តៅក្នុងរយៈពេល១៣ម៉ោងជារៀងរាល់ថ្ងៃ ដោយទទួលបានរបបអាហារបន្តិចបន្តួច ឬក៏គ្មានសោះ អ្នកទោសច្បាស់ជារអ៊ូរទាំជាមិនខាន។ ជាទូទៅបុគ្គលិកមន្ទីរស-២៤តែងតែលបចាំស្តាប់ការរអ៊ូរទាំរបស់ អ្នកទោសទាំងនោះដោយមិនដឹងខ្លួន។

ដោយសារតែអ្នកទោសដែលត្រូវបញ្ជូនទៅកសាងខ្លួនទាំងអស់ត្រូវបានសម្លាប់ចោលដដែល ហើយចំណែកឯបក្សបានបង្កើតកសិដ្ឋានសហករណ៍ជាច្រើនដែលបង្កបង្កើតផលិតផលដំណាំស្រូវដូចគ្នា នោះស៊ីលឃី ស្តូតហ្វ៊ីនស្កី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានសួរថាហេតុអ្វីបានជាជំហានសំខាន់ដំបូងនៃការបង្កើតមន្ទីរស-២៤មានសារសំខាន់ជាងគេ។ ឌុច មិនដឹងពីហេតុផល និងគោលបំណងនៃការបង្កើតមន្ទីរស-២៤ ហើយមិនអាចពន្យល់រៀបរាប់បានទេ។ ជាអកុសល ពេលវេលាមិនអនុញ្ញាតឲ្យស្តូតហ្វ៊ីនស្កី សួរសំណួរបន្តទៀតឡើយ។

## អំណាច និងការទទួលខុសត្រូវរបស់ ឌុច នៅមន្ទីរស-២៤

ដោយសារតែសំណួរសម្រាប់ថ្ងៃនេះពោរពេញដោយភាពក្រៀមក្រំ សហព្រះរាជអាជ្ញា វីលៀម ស្មីតបានព្យាយាមស្វែងរកព័ត៌មានលម្អិតទាក់ទិននឹងអំណាច និងការចេញសម្រេចនៅមន្ទីរស-២៤ ពីព្រោះថា ការរៀបរាប់របស់ ឌុច កាលពីម្សិលមិញនេះមិនត្រឹមត្រូវទៅតាមកសិណសាក្សី ដែល ឌុចនិយាយនៅចំពោះចៅក្រមស៊ើបអង្កេតទេ។ ឌុច បានគូសបញ្ជាក់ថា ខ្លួនមានអំណាចក្នុងការសម្រេចថាតើអ្នកទោសមួយណាដែលត្រូវបញ្ជូនទៅកាន់មន្ទីរស-២១ ឬបឹងជើងឯក ដើម្បីសួរចម្លើយ ទទួលទារុណកម្ម និងសម្លាប់។ ដូច្នេះហើយបានជា ឌុច បានផ្ទេរអំណាចរបស់ខ្លួនឲ្យទៅអនុប្រធានរងរបស់ខ្លួនឲ្យទទួលបន្ទុកលើដំណើរការប្រចាំថ្ងៃរបស់មន្ទីរស-២៤។ ឌុច បានទទួលស្គាល់ថា ខ្លួនបានចេញ«បញ្ជាសម្លាប់មនុស្ស»ជាពាក្យដែល វ៉ាលៀម ស្មីត ហៅមែន។ បន្ថែមលើនេះ ឌុច និយាយថាខ្លួនគ្រាន់តែដឹងថាអ្នកទោសត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ ឬបឹងជើងឯកតែប៉ុណ្ណោះ។ ឌុច បានបន្ថែមទៀតថា «អំណាចត្រូវបានប្រគល់ឲ្យបានតែម្តងគត់»។ ឌុច ទទួលស្គាល់ថា អំណាចរបស់ ឌុច

គ្រប់គ្រងនៅមន្ទីរស-២១ពិតជាមានលក្ខណៈពេញលេញមែន ពីព្រោះថា ឌុច បានដឹងពីលទ្ធផលនៃការសម្លាប់មនុស្សនៅមន្ទីរស-២១ក្នុងរយៈពេលបីឆ្នាំនេះ ប៉ុន្តែ ឌុច មិនបានធ្វើសកម្មភាពអ្វីដើម្បីទប់ស្កាត់ហេតុការណ៍នេះឡើយ ។

កសិណសាក្សីរបស់ ឌុច ទាក់ទិននឹងអំណាចគ្រប់គ្រងនៅមន្ទីរស-២១មានលក្ខណៈខុសពីការពិត ប៉ុន្តែបង្ហាញពីឥរិយាបថសំខាន់របស់ ឌុច ខណៈពេលធ្វើកសិណសាក្សីពីអំណាចគ្រប់គ្រងនៅមន្ទីរស-២១ ។ នៅមន្ទីរស-២១ ឌុច ក្តោបក្តាប់លើដំណើរប្រតិបត្តិការទាំងអស់ដែលត្រូវបានត្រួតពិនិត្យ និងបញ្ចប់កិច្ចការទាំងនោះតាមរយៈថ្នាក់លើរបស់ ឌុច ដំបូងគេគឺ សុន សេន បន្ទាប់មក នួន ជា ។ ទាក់ទិននឹងមន្ទីរស-២១ ឌុច តែងតែអះអាងថា ខ្លួនគ្រាន់តែអនុវត្តតាមបញ្ជាថ្នាក់លើតែប៉ុណ្ណោះ សូម្បីតែពាក់ព័ន្ធនឹងការសួរចម្លើយលើអ្នកទោសមិនសំខាន់ក៏ដោយ ។ នៅមន្ទីរស-២១វិញ ឌុច សារភាពថា មានតែ ឌុច ម្នាក់គត់ដែលមានអំណាចគ្រប់គ្រងអ្នកទោសទាំងអស់ ពីព្រោះអ្នកទោសទាំងនោះត្រូវបានចាត់ទុកថាជា«ជនពាក់កណ្តាលខ្មាំង» ដោយហេតុថាមិនមានភាពច្បាស់លាស់ពីសមាសធាតុទាំងអស់នេះជាមិត្តឬសត្រូវ ។ ឌុច ទទួលស្គាល់ថា ខ្លួនត្រូវតែរាយការណ៍ជូនថ្នាក់លើពីអ្នកទោសសំខាន់មួយចំនួននៅមន្ទីរស-២១ដែល ឌុច មានបំណងបញ្ជូនទៅកាន់មន្ទីរស-២១ ឬបឹងជើងឯក ។

ឌុច បានទទួលស្គាល់ការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលកើតមានឡើងនៅមន្ទីរស-២១ជាច្រើនលើកជាច្រើនសារនៅក្នុងថ្ងៃនេះ ។ ជាចុងក្រោយ វីលៀម ស្មីត បានព្យាយាមទាញយកព័ត៌មានពីដំណើរប្រតិបត្តិ និងអំណាចរបស់ ឌុច ប៉ុន្តែ ឌុច បែរជាមិនឆ្លើយតបនឹងសំណួរទាំងនោះ ហើយចាប់ផ្តើមទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនទៅវិញ ។ ស្មីត បានព្យាយាមបន្តដោយនិយាយថា អ្នករាល់គ្នាពិតជាកោតសរសើរចំពោះការទទួលស្គាល់កំហុសរបស់ ឌុច ប៉ុន្តែសម្រាប់លោកវិញ គឺលោកត្រូវការចម្លើយ ។ ឌុច បានលើកឡើងជាច្រើនលើកថា ក្នុងអំឡុងពេលដែលឧក្រិដ្ឋកម្មបានកើតឡើង ឌុច គិតថាវាជារឿងធម្មតាពីព្រោះ ឌុច គ្រាន់តែជាប៉ូលីសម្នាក់តែប៉ុណ្ណោះ ហើយរដ្ឋាភិបាលនឹងទទួលខុសត្រូវ«ចំពោះមុខទំព័រប្រវត្តិសាស្ត្រ» ។ ឌុច បានសុំបន្ទោសឲ្យ ប៉ុល ពត សម្រាប់ការបង្កើតមាគ៌ាបក្សដ៏អាក្រក់នេះ ប៉ុន្តែ ឌុច ក៏សូមទទួលស្គាល់ថាខ្លួនក៏ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សរាប់ពាន់នាក់ដែលបានអនុវត្តមាគ៌ាបក្សនេះដែរ ។ «ខ្ញុំសូមទទួលស្គាល់ថាខ្ញុំគឺជាឧក្រិដ្ឋជនក្នុងចំណោមឧក្រិដ្ឋជនទាំងនោះ» ។

ដូចធម្មតា មេធាវីការពារក្តីតែងតែចោទសួរសំណួរខ្លី ហើយជាពិសេសគឺថ្ងៃនេះតែម្តងពីព្រោះថា ហ្វ្រង់ស័រ រូ មេធាវីការពារក្តីអន្តរជាតិអវត្តមាន ហើយគ្មានមេធាវីជំនួស ។ ដូចជា យុទ្ធសាស្រ្តថ្មី ការ សាវុត្ថ មេធាវីការពារក្តីជាតិបានព្យាយាមចាត់ទុក ឌុច ជាជនរងគ្រោះនៃនយោបាយកសាងខ្លួនរបស់បក្ស ។ ឌុច បានរៀបរាប់ពីមូលហេតុដែលខ្លួនចង់ក្លាយជាអ្នកបំរើឲ្យរបបកុម្មុយនីស្ត ប៉ុន្តែក្នុងមួយរំពេចភ្នែកសោះ ឌុច បានក្លាយជាមនុស្សថ្មីម្នាក់ដោយប្រែក្លាយពីគ្រូបង្រៀនគណិតវិទ្យាដែលមានឈ្មោះថា កាំង ហ្គេកអ៊ាវ មកជាប្រធានគុកដែលមានឈ្មោះថា ឌុច ។ ឌុច បាននិយាយថា ឥឡូវនេះ“ខ្ញុំសូមសំពះគោរពប្រជាជនកម្ពុជាទាំងអស់” ។ ឌុច បានសួរទៅកាន់ចៅក្រមអង្គជំនុំជម្រះថា “តើអ្នកយល់ថាខ្ញុំជាមនុស្សថ្មីម្នាក់មែនឬ” ?

## ការចាត់ចែងពេលវេលា

តាមរបាយការណ៍កាលពីដើមសប្តាហ៍នេះ ការចាត់ចែងរបស់អង្គជំនុំជម្រះថ្មីដែលសម្រេច ដោយចៅក្រមអង្គជំនុំជម្រះបានចោទជាបញ្ហាគួរឲ្យព្រួយបារម្ភ ។ សម្រាប់ប្រធានបទសំខាន់ទាក់ទិននឹងមន្ទីរស-២៤ ព្រះរាជអាជ្ញាបានផ្តល់រយៈពេលត្រឹមតែ១ម៉ោងដើម្បីសួរសំណួរ ហើយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទទួលបាន១ម៉ោងដែរមានន័យថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមមានពេល១៥នាទី ដើម្បីចោទសួរសំណួរតែប៉ុណ្ណោះ ។ រយៈពេលកំណត់សម្រាប់មេធាវីការពារក្តីមិនទាន់បានប្រកាសនៅឡើយទេ ប៉ុន្តែលោក ការ សាវុត្ថ បានសម្រេចសួរត្រឹមតែជាងមួយម៉ោងដោយខ្លួនឯង ។

បើទោះបីជារយៈពេលនេះ ហាក់បីដូចជាមានលក្ខណៈសមរម្យសម្រាប់អ្នកតាមដានពីមជ្ឈដ្ឋានខាងក្រៅក៏ដោយ ក៏នៅក្នុងបន្ទប់សវនាការរយៈពេលប៉ុណ្ណោះមិនគ្រប់គ្រាន់ទេ ។ ដោយសារតែមានការបកប្រែភ្លាមៗតែម្តង នោះភាគីនីមួយៗត្រូវតែនិយាយមួយៗយឺតៗ ហើយជាញឹកញាប់ត្រូវតែនិយាយសារជាថ្មីម្តងទៀត ។ សំណួរមួយត្រូវតែចោទសួរដោយវិធីជាច្រើនបែបដើម្បីឲ្យ ឌុច ឆាប់យល់ ហើយធ្វើការឆ្លើយតប ។ នៅពេលដែលភាគីណាមួយដាក់ឯកសារ ឬវីដេអូនៅចំពោះមុខអង្គជំនុំជម្រះ ភាគីនោះត្រូវតែធ្វើការស្នើសុំជាមុនសិនពីប្រធានចៅក្រម ហើយប្រសិនបើបញ្ហាបច្ចេកទេស កើតមានឡើងនោះដំណើរការនីតិវិធីក៏ត្រូវតែពន្យារពេលដែរ ។

ថ្ងៃនេះ សហព្រះរាជអាជ្ញា វីលៀម ស្មិត បានដាក់សម្ពាធលើ ឌុច ដើម្បីឲ្យ ឌុច ធ្វើការគូសបញ្ជាក់ពីព័ត៌មានមិនស៊ីគ្នាទាក់ទិននឹងរបាយការណ៍រៀបរាប់ពីមន្ទីរស-២១ ដែលឈានទៅរកបញ្ហាសំខាន់ៗស្តីពីការដឹងឮរបស់ ឌុច ពីដំណើរប្រតិបត្តិការប្រចាំថ្ងៃរបស់មន្ទីរស-២១នោះ ។ ឌុច បានទទួលស្គាល់ថាការចងចាំរបស់ ឌុច ទាក់ទិននឹងបញ្ហាដែលកើតមានឡើងទាំងនោះមានលក្ខណៈស្រពិចស្រពិល ។ ដូច្នេះ ឌុច បានស្នើសុំលោក វីលៀម ស្មិត ថាតើលោកអាចយកឯកសារមួយចំនួនមកជួយរំឭកការចងចាំរបស់ ឌុច បានដែរឬទេ ។ ដោយកត់សម្គាល់ឃើញថាមានពេលត្រឹមតែ១០នាទី វីលៀម ស្មិត បាននិយាយថាលោកមិនមានពេលគ្រប់គ្រាន់ទេ ។ ជាទូទៅព្រះរាជអាជ្ញា តែងតែដាក់ឯកសារជាច្រើននៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែថ្ងៃនេះព្រះរាជអាជ្ញាមិនបានដាក់ឯកសារដូចសព្វមួយដងនោះទេ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក៏មិនបានដាក់ឯកសារណាមួយនៅចំពោះមុខអង្គជំនុំជម្រះដូចគ្នាដែរ ។ ប្រសិនបើឥទ្ធិពលរបស់យុទ្ធសាស្ត្រចាត់ចែងដំណើរការរបស់អង្គជំនុំជម្រះពិតជាដាក់កម្រិតលើ បញ្ហាដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះមែននោះ បញ្ហានេះគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ។ នៅក្នុងវិធានផ្ទៃក្នុង៨៧.២របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា «សេចក្តីសម្រេចរបស់ចៅក្រមត្រូវតែធ្វើឡើង ដោយផ្អែកលើភស្តុតាងដែលដាក់នៅចំពោះចៅក្រមដែលតម្រូវឲ្យធ្វើការត្រួតពិនិត្យ» ដូចដែលបានធ្វើឡើងតាមភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង ។

គួរឲ្យចម្លែក នៅពេលដែលចៅក្រមបានព្យាយាមធ្វើឲ្យការប្រើប្រាស់ពេលវេលានៅក្នុងអង្គសវនាការកាន់តែមានប្រសិទ្ធិភាពនោះ ដំណើរការរបស់អង្គជំនុំជម្រះហាក់បីដូចជាប្រព្រឹត្តទៅក្នុងល្បឿនយឺតដដែល ។ ដំណើរការនីតិវិធីក្នុងរយៈពេលបីថ្ងៃចុះក្រោយនេះបានបញ្ចប់ទៅមុនពេលកំណត់ ប៉ុន្តែ អ្វីដែលមាននៅក្នុងកាលវិភាគមិនត្រូវបានដំណើរទៅមុខទាល់តែសោះ ។

នាពេលចុងបញ្ចប់នៃដំណើរការនីតិវិធីក្នុងថ្ងៃនេះ លោកប្រធានចៅក្រម និល ណុន បានប្រកាសដោយមោទនៈភាពថាការសួរដេញដោលពីមន្ទីរស-២១ត្រូវបានបញ្ចប់មុនកាលវិភាគរបស់តុលាការ ។ ខ្ញុំគិតថាព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឡប់ទៅផ្ទះវិញដោយសេចក្តីមោទនៈភាពនេះទេ ផ្ទុយទៅវិញទាំងព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនឹងចំណាយពេលធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ វិញដោយចោទសួរខ្លួនឯងពីសំណួរដែលខ្លួនមិនមានឱកាសសួរ ។